# សេចក្តីជូនដំណឹងដល់សិក្ខាកាមទាំងអស់

厚生労働省

## នេះជាពត៍មានណែនាំប្រសិនបើសិក្ខាកាមមិនអាចបន្តធ្វើការនៅក្នុងប្រទេសជប៉ុន
## ～អនុវត្តន៍បានសំរាប់អ្នកកាន់កាតសំគាល់ខ្លួន「សកម្មភាពពិសេស（មិនអាចធ្វើការបាន）」～

ក្នុងនាមជាសិក្ខាកាម អ្នកត្រូវបានការពារដោយច្បាប់ការងាររបស់រដ្ឋាភិបាលក្នុងប្រទេសជប៉ុន។
ដោយសារការរីករាលដាលនៃជំងឺឆ្លងថ្មីក្ស័ណាសិក្ខាកាមត្រូវបាត់បង់ការងារ ឬត្រូវបណ្តេញចេញពីក្រុមហ៊ុនហើយត្រូវរកការងារថ្មីនោះ ខាងយើងក៏មានប្រព័ន្ធដើម្បីរកការងារសិក្ខាកាមផងដែរ។បើអ្នកមានចំណាប់អារម្មណ៍សូមកុំស្ទាក់ស្ទើរក្នុងការប្រើប្រាស់វា។

## ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)

**ក្នុងអំឡុងពេលអ្នកធ្វើការបានបាត់បង់ការងារហើយអ្នកកំពុងតែស្វែងរកការងារខាងយើងផ្តល់អត្ថប្រយោជន៍ចាំបាច់ដើម្បីធ្វើឱ្យជីវិតរបស់ពួកគេអាចរស់នៅបានដោយមានស្ថេរភាព។ បើយើងមានករណីចាំបាច់អ្នកអាចស្នើសុំជំនួយយកប្រាក់ធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន) ។ (ចំណាំសិក្ខាកាមក៏មានសិទ្ធប្រើប្រាស់ប្រព័ន្ធនេះដូចជនជាតិជប៉ុនផងដែរ)**

**អ្នកអនុវត្តន៍**

- **សិក្ខាកាមត្រូយបានបណ្តេញចេញពីការងារទាំងមិនទាន់ចប់អាណត្តិនឹងកំពុងរកការងារថ្មី**
- **ក្រោយពីអាណត្តិសិក្ខាកាម នឹងសិក្ខាកាមមិនអាចវិលត្រលប់ទៅមាតុភូមិហើយស្វែងរកការងារបន្ត**

※យ៉ាងណាមិញ សំរាប់អ្នកអនុវត្តន៍គឺតម្រូវអោយប្តូរ ទិដ្ឋាការទាំងនេះ 「សិក្ខាកាម」「សកម្មភាពពិសេស」（មិនអាចធ្វើការបាន） ឬ「ស្នាក់អាស្រ័យរយៈពេលខ្លី」（គិតត្រឹមខែ៥ទី២០ ）「សិក្ខាកាម」）ជាមុនសិន។

### ១ ការដាក់ពាក្យធ្វើការនៅកន្លែងស្វែងរកការងារ

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភមូលដ្ឋានបន្ទាប់ពីឈប់រឺចាកចេញពីការងារអ្នកត្រូវដាក់ពាក្យសុំរកការងារនៅកន្លែងស្វែងរកការងារ។

### ២ ការធានារ៉ាប់រងការងារត្រូវមានរយៈពេល១២ខែឬច្រើនជាងនេះ

បន្ទាប់ពីចាកចេញពីការងារអ្នកត្រូវតែមានការបង់ធានារ៉ាប់រងការងារយ៉ាងហោចណាស់១២ខែក្នុងរយៈពេល២ឆ្នាំមុនថ្ងៃដែលបានចាកចេញពីការងារ។ប៉ុន្តែបើសិនជាខាងក្រុមហ៊ុនមិនមានការក្សីយធុនទេតែក្រុមហ៊ុនត្រូវបញ្ឈប់បុគ្គលិកមួយចំនួននោះការធានារ៉ាប់រងការងារត្រូវមានយ៉ាងហោចណាស់៦ខែក្នុងរយៈពេល១ឆ្នាំមុនថ្ងៃចាកចេញពីការងារ។

**<វិធីស្នើសុំយកការធានារ៉ាប់រង >(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)**



ក្រុមហ៊ុនដែលត្រូវបានកាត់បន្ថយម៉ោងធ្វើការរបស់បុគ្គលិកហើយអាចឈានដល់ការបញ្ឈប់បុគ្គលិកក្នុងករណីណាមួយពួកគេអាចស្នើរប្រាក់ឧបត្ថម្ភបានដែលតំរូវអោយសិក្ខាកាមបំពេញតាមតម្រូវការជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយដើម្បីចៀសវាងគុណវិបត្តិបុគ្គលិកពួកគេអាចប្រើប្រាស់ប្រព័ន្ធធានារ៉ាប់រងការងារពេលឈប់សម្រាកបាន។ លើសពីនេះ នៅចន្លោះពេលសំរាកសិក្ខាកាមមានសិទ្ធិសំរាកនឹងថែមទាំងមានសិទ្ធិទទួលប្រាក់ម៉ោងដែលសំរាកផងដែរ។

※ លើសពីនេះទៅទៀតក្នុងមេត្រាទី២៦នៃច្បាប់ស្ដីពីស្តង់ដារការងារប្រសិនបើក្រុមហ៊ុនបានបញ្ឈប់បុគ្គលិកពួកគេត្រូវទទួលប្រាក់ជំនួយពីក្រុមហ៊ុនក្នុងរយះពេលឈប់សម្រាកដើម្បីធានាកំរិតជីវភាពអប្បបរមាររបស់បុគ្គលិកដែលបានសន្មត់ជាមុន។

**សម្រាប់ពតិមានបន្ថែមសូមទាក់ទងសាកសួរខាងក្រោមហើយយើងក៏ផ្ដល់ពត៏មានតាមគេហទំព័រផងដែរ**

● **ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)**

➢ **ការិយាល័យសន្តិសុខការងារសាធារណះការិយាល័យរដ្ឋបាលខេត្ត （កន្លែងស្វែងរកការងារ）**

**https://www.mhlw.go.jp/kyujin/hwmap.html**

● **សូមទំនាក់ទំនងទៅល័ក្ខខ័ណ្ឌការងារប្រាក់ឈ្នួលរួមទាំងប្រាក់ជំនួយពេលឈប់សម្រាក ：**

➢ **ទូរស័ព្ទពិភាគសារយោបល់សម្រាប់ពលករបរទេស ទូរស័ព្ទបន្ទាន់សម្រាប់ពិគ្រោះយោបល់ល័ក្ខខ័ណ្ឌការងារនឹងពិគ្រោះយោបល់សម្រាប់ជនបរទេស ：**

**https://www.check-roudou.mhlw.go.jp/soudan/foreigner.html**

● **ពត៏មានទាក់ទងនឹងទិដ្ឋាការវីសារ**

➢ **ផបសាយការិយាល័យច្បាប់**

**http://www.moj.go.jp/content/001319640.pdf**

## សេចក្ដីណែនាំរបស់អង្គការបណ្ដុះបណ្ដាលបច្ចេកទេសនឹងបណ្ដាញទូរស័ព្ទពិគ្រោះយោបល់នៃភាសាកំណើត

អង្គការបណ្ដុះបណ្ដាលបច្ចេកទេសបរទេស

- ពេលមានអារម្មណ៍ព្រួយចំពោះការងារឬជីវភាពប្រចាំថ្ងៃ
- ពេលមានអារម្មណ៍ថាប្រាក់ឈ្នួលការងារមិនទទួលបានគ្រប់គ្រាន់រឺខុសតាមគោលការណ៍
- ពេលមានកំហុសឆ្គងហើយនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវិញ
- ពេលដែលមិនយល់ច្បាស់អំពីច្បាប់ប្រទេសជប៉ុនរឺមិនមាននរណាម្នាក់ពិគ្រោះយោបល់ជាមួយ

ទទួលពិគ្រោះយោបល់ជាច្រើនរបស់សិក្ខាកាមពលករនៅប្រទេសជប៉ុនជាមួយភាសាដើមកំនើតរបស់អ្នក
សម្រាប់ពត៏មានសម្អិតសូមចុលមើលគេហទំព័រខាងក្រោម （https://www.otit.go.jp）

**ទូរស័ព្ទពិគ្រោះយោបល់ជាភាសារកំនើត （១១:00～១៩:00ល្ងាច）**

| | | | |
|---|---|---|---|
| • ភាសាវៀតណាម | រាល់សប្ដាហ៍ | ： ច័ន្ទ～សុក្រ | TEL ： ០១២០ー២៥០ー១៦៨ |
| • ភាសាចិន | រាល់សប្ដាហ៍ | ： ច័ន្ទ • ពុធ • សុក្រ | TEL ： ០១២០ー២៥០ー១៦៩ |
| • ភាសាឥណ្ឌូនេស៊ី | រាល់សប្ដាហ៍ | ： អង្គារ • ពុធ | TEL ： ០១២០ー២៥០ー១៩២ |
| • ភាសាហ្វីលីពីន | រាល់សប្ដាហ៍ | ： អង្គារ • សៅរ៍ | TEL ： ០១២០ー២៥០ー១៩៧ |
| • ភាសាអង់គ្លេស | រាល់សប្ដាហ៍ | ： អង្គារ • សៅរ៍ | TEL ： ០១២០ー២៥០ー១៤៧ |
| • ភាសាថៃ | រាល់សប្ដាហ៍ | ： ពុធ • សៅរ៍ | TEL ： ០១២០ー២៥០ー១៩៨ |
| • ភាសាខ្មែរ | រាល់សប្ដាហ៍ | ： ព្រហស្បហ៍ | TEL ： ១២០ー២៥០ー៣៦៦ |
| • ភាសាមិយ៉ាន់ម៉ា | រាល់សប្ដាហ៍ | ： សុក្រ | TEL ： ០១២០ー២៥០ー៣០២ |